# រោងចក្រកាត់ដេរសម្លៀកបំពាក់ ហ៊ី ហ្វុង អ៊ិនធើប្រាយ ឯ.ក

HE FONG ENTERPRISE Co.,LTD.

អាសយដ្ឋានៈ ភូមិ ព្រៃស សង្កាត់ ភ្នំពេញថ្មី ខណ្ឌ សែនសុខ រាជធានីភ្នំពេញ

---

## កិច្ចព្រមព្រៀង
## ស្តីពី
## ការព្យួរកិច្ចសន្យាការងារកម្មករនិយោជិត
## រវាង

**នាយករោងចក្រ និងសហជីព ប្រតិភូបុគ្គលិក ជាតំណាងកម្មករនិយោជិត**

**កម្មវត្ថុៈ** សំណើសុំព្យួរកិច្ចសន្យាការងារ កម្មករនិយោជិតចំនួន ១៧៥ នាក់រយៈពេល៦០ថ្ងៃ។

**យោងៈ** មាត្រា៧១ និងមាត្រា៧២ នៃច្បាប់ការងារ របស់ព្រះរាជាណាចក្រកម្ពុជា។

សេចក្តីណែនាំស្តីពីការព្យួរកិច្ចសន្យាការងារ និងការផ្អាកបង់ភាគទាន ប.ស.ស សម្រាប់រោងចក្រ សហគ្រាសគ្រឹះស្ថានក្នុងវិស័យកាត់ដេរ និងទេសចរណ៍ដែលរងផលប៉ះពាល់ធ្ងន់ធ្ងរដោយសារជំងឺកូវីដ-១៩ លេខៈ០៤៥/២០ ក.ប/ស.ណ.ន.ខ.ល ចុះថ្ងៃ អង្គារ ១៣កើត ខែ មាឃ ឆ្នាំជូត ទោស័ក ពុទ្ធសករាជ ២៥៦៤ ត្រូវនឹងថ្ងៃទី ២៦ ខែ មករា ឆ្នាំ២០២១។

ថ្ងៃទីម្ភៃប្រាំមួយ ខែ មករា ឆ្នាំ ពីរពាន់ម្ភៃមួយ វេលាម៉ោង១០និង៣០នាទី មានកិច្ចប្រជុំនៅរោងចក្រកាត់ដេរសម្លៀកពាក់ **ហ៊ី ហ្វុង អ៊ិនធើប្រាយ** ឯ.ក ។

បានព្រមព្រៀង និងឯកភាពគ្នាដូចខាងក្រោម

១.ព្យួរកិច្ចសន្យាការងារកម្មករនិយោជិតគ្រប់ផ្នែកទាំងអស់សរុបចំនួន ១៧៥នាក់រយៈពេល ៦០ថ្ងៃដោយគិតចាប់ពីថ្ងៃទី២៦ ខែ មករា រហូតដល់ថ្ងៃទី២៦ ខែមីនា ឆ្នាំ២០២១។

២.នាយករោងចក្រ និងសហជីព ប្រតិភូបុគ្គលិក ជាតំណាងកម្មករនិយោជិត បានព្រមព្រៀង ផ្តល់ប្រាក់៣០ដុល្លារ ពីរោងចក្រ និងរាជរដ្ឋាភិបាលឧបត្ថម្ភ៤០ដុល្លាអាមេរិក។

៣.ចូលធ្វើការវិញនៅថ្ងៃទី២៧ ខែមីនា ឆ្នាំ២០២១។

កំណត់ហេតុនៃកិច្ចព្រមព្រៀងនេះ បានចប់សព្វគ្រប់នៅថ្ងៃ ខែ ឆ្នាំដដែលវេលា១១ និង០០នាទី ក្រោមបរិយាកាសរីករាយ ឯកភាពគ្នា និងភាពសិទ្ធស្នាលដ៏ក្រៃលែង។

ថ្ងៃ អង្គារ ១៣កើត ខែ មាឃ ឆ្នាំជូត ទោស័ក ព.ស.២៥៦៤

រាជធានីភ្នំពេញ ថ្ងៃទី ២៦ ខែ មករា ឆ្នាំ២០២១

ស្នាមមេដៃស្តាំសហជីព ប្រតិភូបុគ្គលិក ជាតំណាងកម្មករនិយោជិត

ហត្ថលេខា និងត្រា

ជ. ម្ចាស់ បុនាយក

HE FONG ENTERPRISE CO., LTD.

KINGDOM OF CAMBODIA